# ទំនុកដំកើងក្នុងការថ្វាយបង្គំព្រះ

**ទំនុកដំកើងប្រើនៅក្នុងព្រះវិហារក្នុងការថ្វាយបង្គំ**

ការប្រើទំនុកដំកើងនៅក្នុងព្រះវិហារត្រូវបានសម្រេចប្រើ មុនការបំផ្លាញព្រះវិហារ ដោយ Titus ក្នុងឆ្នាំ ៧0AD.

ថ្ងៃដំបូង ទំនុកដំកើង ២៤

ថ្ងៃទីពីរ ទំនុកដំកើង ៤៨

ថ្ងៃទីបី ទំនុកដំកើង ៨២

ថ្ងៃទីបួន ទំនុកដំកើង ៩៤

ថ្ងៃទីប្រាំ ទំនុកដំកើង ៨១

ថ្ងៃទីប្រាំមួយ ទំនុកដំកើង ៩៣

ថ្ងៃទីប្រាំពីរ ទំនុកដំកើង ៩២

**ទំនុកដំកើងប្រើនៅក្នុងសាលាប្រជុំ ក្នុងការថ្វាយបង្គំ**

សាលាប្រជុំត្រូវបានបង្កើតឡើងភ្ជាប់នឹងព្រះវិហារ ហើយមានការទាក់ទងទៅនឹងថ្វាយបង្គំព្រះនៅព្រះវិហារ ដូចនេះការថ្វាយបង្គំនៅសាលាប្រជុំមានការទាក់ទងទៅនឹងការថ្វាយបង្គំនៅព្រះវិហារ។ លោក John Alexander Lamb បានផ្ដាល់ការ៦យ៉ាងដែលត្រូវបានប្រកាសនៅក្នុងសាលាប្រជុំក្នុងការថ្វាយបង្គំព្រះ៖

១. ទំនុកដំកើងត្រូវបានគេសូត្រផ្នែកខ្លះ ឬទាំងអស់នៅក្នុងការថ្វាយបង្គំ

២. ទំនុកដំកើងពីព្រះ ឬទំនុកដំកើងដែលទាក់ទងនឹងថ្ងៃផ្សេងៗ ឬវិធីបុណ្យ ត្រូវបានដាក់តម្រូវឲ្យអានក្នុងការធ្វើពិធីផ្សេងៗ៖

| | |
|---|---|
| ទំនុកហាលេលូយា<br><br>(ទំនុកដំកើង ១១៣-១១៨) | ថ្ងៃបុណ្យចូលខែថ្មី<br><br>បុណ្យរំលង<br><br>បុណ្យថ្ងៃទី៥០<br><br>បុណ្យបារាំ (លេវី. ២៣:៣៣-៣៦) |

| | |
|---|---|
| | ពិធីឆ្លង (ពិធីសម្ពោធ) |
| ទំនុកដំកើង ៧ | បុណ្យពោរ (បុណ្យពួរីម) |
| ទំនុកដំកើង ១២ | ថ្ងៃទី៨នៃបុណ្យបារាំ |
| ទំនុកដំកើង ៣០ | បុណ្យឆ្លង (បុណ្យសម្ពោធ) |
| ទំនុកដំកើង ៤៧ | បុណ្យចូលឆ្នាំថ្មី |
| ទំនុកដំកើង ៩៨ និង ១០៤ | បុណ្យចូលខែថ្មី |
| ទំនុកដំកើង ១០៣ និង ១៣០ | ថ្ងៃឲ្យបានធួននឹងបាប (ថ្ងៃបុណ្យរំដោះបាប) |

៣. ខជាក់លាក់មួយចំនួនត្រូវបានសូត្រនៅពេលពាក់ផាហ៊ុម(កន្សែង)សេចក្ដីអធិស្ឋាន ទំនុកដំកើង ៣៦:៧-១០ ត្រូវបានអាន ហើយបន្ទាប់ពីអាន រមុមច្បាប់តូរ៉ាត្រូវបានយកចេញពីអាសនា នោះអ្នកដឹកនាំក៏លើកវាឡើង ហើយនិយាយថា ទំនុកដំកើង ៣៤:៣ ចែងថា "ចូរដំកើងព្រះយេហូវ៉ាជាមួយនឹងខ្ញុំចុះ ចូរយើងព្រមគ្នាលើកព្រះនាមទ្រង់ឡើង"

៤. អ្នកប្រាជ្ញព្រះគម្ពីរមួយចំនួនបាននិយាយថា ទំនុកដំកើងត្រូវបានអានជាកងក្នុងរយៈពេល៣ឆ្នាំ ដូចជាច្បាប់តូរ៉ាត្រូវបានអាននៅក្នុងភីលីស្ទីន។ ទំនុកដំកើងចំនួន១៦០ជំពូកគឺមានគ្រប់សំរាប់អានក្នុងរយៈពេល៣ឆ្នាំ។ តែទុកជាយ៉ាងនេះក្ដី ពុំមានភ័ស្ដុតាងណាគាំទ្រមាននៅក្នុងសៀវភៅថ្វាយបង្គំរបស់ជនជាតយូដាឡើយ។

៥. ការអានឆ្លងឆ្លើយគ្នានៃកណ្ឌទំនុកដំកើងត្រូវបានបញ្ចូលនៅក្នុងការថ្វាយបង្គំក្នុងសាលាប្រជុំ។ មានបទសរសើរមួយចំនួននៃទំនុកដំកើងត្រូវបានប្រើនៅក្នុងកម្មវិធីថ្វាយបង្គំព្រះ។

៦. មានសេចក្ដីអធិស្ឋានជាច្រើនត្រូវបានតែង ដែលដកស្រង់ចេញពីកណ្ឌទំនុកដំកើង មានឃ្លា និងពាក្យវេកសព្ទមួយចំនួនដកស្រង់ជាខ្សែៗ។

**ទំនុកដំកើងប្រើនៅក្នុងការថ្វាយបង្គំគ្រីស្ទាន**

ការស្នងមតិ ចំពោះការប្រើទំនុកដំកើងនៅក្នុងការថ្វាយបង្គំរបស់គ្រីស្ទានមានការលំបាកយល់ ដូចនៅក្នុងការស្វែងយល់ពីការថ្វាយបង្គំរបស់យូដា។

១. ក្រុមជំនុំដើមរហូតដល់ការកែប្រែ

២. ទំនុកដំកើងក្នុងសម័យនៃការកែប្រែរបស់ពួកជំនុំ

៣. ទំនុកដំកើងក្នុងសម័យសតវត្សទី២១

**ឆ្លុះបញ្ចាំងពីជីវិតខ្លួនក្នុងការថ្វាយបង្គំ និងទំនុកដំកើង**

តើយើងមានដែលទន្ទិញចាំនូវទំនុកដំកើងណា ដើម្បីរក្សាក្នុងចិត្តក្នុងការថ្វាយបង្គំព្រះពេលទៅណាមកណា?

តើយើងបានប្រើទំនុកដំកើងក្នុងការថ្វាយបង្គំដែរឬទេ?

តេយើងបានតែងទំនុកដំកើងផ្ទាល់ខ្លួនក្នុងការថ្វាយបង្គំព្រះដែរឬទេ?